ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍

# កិច្ចប្រជុំប្រចាំត្រីមាសទីពីរក្រុមការងារបច្ចេកទេស

# ថ្នាក់ជាតិ បុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

# ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ នៅភោជនីយដ្ឋាន ទន្លេបាសាក់២

## ១-សាវតា:

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពិសេសក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ សហការ និងគាំទ្រថវិកាដោយអង្គការសេវាសង្គមសុខភាពបុរសបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទីបី នៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅភោជនីយដ្ឋានទន្លេបាសាក់២ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ដោយមានវត្តមានមកពីក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមគោលដៅមកពីសហគមន៍ផ្ទាល់ មន្ត្រីលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ដដូចជាខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងរាជធានីភ្នំពេញប្រមាណជាសែសិបនាក់។

## ២-គោលបំណង:

១. បង្ហាញពីរបាយការណ៍វឌ្ឍនភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំត្រីមាសទីបី។

២. ពិនិត្យមើលបច្ចុប្បន្នភាព បទពិសោធន៍ការផ្តល់សេវាពិនិត្យសុខភាព និងឧបសគ្គ នានាលើបទអន្តរាគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ និងការស្រាវជ្រាវអត្រាប្រេវ៉ាឡង់មេរោគអេដស៍លើក្រុមស្រីស្រស់ នៅក្នុងប្រទេសកម្ពុជា។

តាមរយៈនៃកិច្ចប្រជុំ សមាជិក សមាជិកាក្រុមការងារបច្ចេកទេសទាំងអស់រំពឹងថា នឹងទទួលបាននូវអនុសាសន៍ល្អៗពីកិច្ចប្រជុំប្រចាំត្រីមាស និងដឹងពីស្ថានភាពប្រឈមនៃក្រុមស្រីស្រស់ ដើម្បីរៀបចំផែនការសកម្មភាពសំរាប់អនុវត្តត្រីមាសបន្ទាប់។

## ៣-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន:

កាលបរិច្ឆេទ : ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៦

ទីកន្លែង : នៅភោជនីយដ្ឋាន ទន្លេបាសាក់២

វត្តមាន : ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រុមគោលដៅមកពីសហគមន៍ផ្ទាល់ មន្ត្រីលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត រួមមានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងរាជធានីភ្នំពេញ។

## ៤-វិធីសាស្ត្រ:

កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានប្រើប្រាស់វិធីសាស្ត្រសំខាន់ៗមួយចំនួនដូចជា បទបង្ហាញជាស្លាយ ការពិភាក្សាក្រុមធំ វេទិកាសំណួរចំឡើយរវាងអ្នកចូលរួមនិងវាគ្មិន និងការផ្តល់បទសំភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការផ្តល់ជាអនុសាសន៍ ដើម្បីរៀបចំផែនការសកម្មភាពសំរាប់អនុវត្តការងារនៅត្រីមាសក្រោយ។



ឯកឧត្តមប្រធាន និងសមាជិកនៃកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិ

**៥-លទ្ធផល:**

កាលពីថ្ងៃព្រហស្ប៍ទី១៥ ខែកញ្ញា ឆ្នាំ២០១៦ វេលាម៉ោង៨:៣០នាទីព្រឹក នៅភោជនីយដ្ឋានទន្លេបាសាក់២ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ សហការជាមួយអង្គការសេវាសង្គមសុខភាពបុរស បានរៀបចំនូវកិច្ចប្រជុំប្រចាំត្រីមាសទីបីរបស់ខ្លួន ក្រោមការសម្របសម្រួល និងដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តមវេជ្ជ.**តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការឧបត្ថម្ភថវិកាពីទីភ្នាក់ងារអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ USAID ក្រោមគម្រោងផ្លែកស៊ីបតាមរយៈអង្គការសេវាសង្គមសុខភាពបុរសដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

១. មតិស្វាគមន៍ និងបើកកិច្ចប្រជុំ

មតិស្វាគមន៍ និងបើកកិច្ចប្រជុំ ដោយឯកឧត្តមប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់សមាជិក សមាជិកា ដែលបានចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ និងបានអរគុណដល់អង្គការសេវាសង្គមសុខភាពបុរស ដែលតែងតែឧបត្ថម្ភថវិកាដល់ការរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនេះឡើង។ ឯកឧត្តមអគ្គលេខាធិការមានប្រសាសន៍ថា កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងបង្ហាញពីរបាយការណ៍វឌ្ឍនភាពនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំត្រីមាសទីបី និងធ្វើបច្ចុប្បន្នភាពបទពិសោធន៍នៃការផ្តល់សេវាពិនិត្យសុខភាព និងឧបសគ្គនានាលើបទអន្តរាគមន៍បង្ការក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ និងការស្រាវជ្រាវអត្រាប្រេវ៉ាឡង់មេរោគអេដស៍លើក្រុមស្រីស្រស់នៅក្នុងប្រទេសកម្ពុជា។ ជាមួយគ្នានេះ ឯកឧត្តមប្រធានអង្គប្រជុំបានមានប្រសាសន៍បន្តទៀតថា តាមការសិក្សាពីស្ថានភាពរបស់ប្រទេសកម្ពុជាមានក្រុមបីដែលអាចជាឈ្នាន់នៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ជាថ្មី។ បីក្រុមនោះរួមមានស្ត្រីធ្វើការនៅតាមគ្រឹះស្ថានកំសាន្ត ក្រុមប្រើប្រាស់គ្រឿងញៀន និងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។ ឯកឧត្តមប្រធានបានមានប្រសាសន៍បន្ថែមទៀតថា ក្នុងបទអន្តរាគមន៍បង្ការពិសេសលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដែលមានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលជាស្ថាប័នរដ្ឋ និងអង្គការជាដៃគូ ត្រូវតែបង្កើតក្រុមការងារជាក់លាក់មួយដើម្បីងាយស្រួលតាមដានលំអិតលើក្រុមនេះ។ ដូច្នេះហើយបានជាថ្ងៃនេះ យើងបានរៀបចំកិច្ចប្រជុំនេះឡើងដើម្បីបង្ហាញជូននូវកង្វះជាច្រើន ទោះបីជាយើងមិនមែនជាក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់តែប្អូនៗក្មួយៗជាកូនចៅប្រជាពលរដ្ឋយើងជាជនជាតិយើងដែលយើងត្រូវយកចិត្តទុកដាក់ និងរិះរកវិធីសាស្ត្រថ្មីៗក្នុងបទអន្តរាគមន៍ ពិសេសផ្តោតលើខេត្តសំខាន់ៗ និងក្រុមលាក់មុខ ដើម្បីសម្រេចបាននូវគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ២០២៥ ។

២.ជាកិច្ចបន្តការធ្វើបទបង្ហាញ៖

**២.១ ការបង្ហាញពីរបាយការណ៍វឌ្ឍនភាពបទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ឆ្នាំ២០១៦៖**

នៅក្នុងបទបង្ហាញនោះ វាគ្មិនបានបង្ហាញពីលទ្ធផលដែលបានសម្រេច ពីឧបសគ្គនានា និងពីកង្វះថវិការបស់ក្រុមការងារក្នុងការអនុវត្តន៍ការងារ។ តាមរយៈរបាយការណ៍នេះ ក៏បានបង្ហាញពីកិច្ចសម្របសម្រួល និងសហការរវាងអាជ្ញាធរមូលដ្ឋាន និងអង្គការជាដៃគូ។ ជាមួយគ្នានោះក៏បានលើកជាសំណូមពរ ឬផ្តល់ជាអនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពសំរាប់អនុវត្តបន្ត។

២.១.១ លទ្ធផលសម្រេចបានរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៦៖

- ការសម្របសម្រួល និងការកសាងសមត្ថភាព៖

១.បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៥ ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

២.បានកែសម្រួលសេចក្តីសម្រេចស្តីពីក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣.បានប្រជុំក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំខែ និងប្រចាំត្រីមាសជាទៀងទាត់។

៤. បានរៀបចំផែនការសកម្មភាពលំអិតប្រចាំឆ្នាំ២១០៦។

៥.បានរៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិ ជាមួយអ្នកផ្តល់សេវាសុខភាព គ្រូសារអាណាព្យាបាល និងអាជ្ញាធរដែនដីស្តីពីការរើសអើង និងការទទួលសេវាសុខភាព នៅខេត្តពោធិ៍សាត់ បាត់ដំបង និងសៀមរាប។

៦.ប្រមូលរបាយការណ៍ពីអង្គការដៃគូដែលធ្វើការងារជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

៧.ពង្រឹងសមត្ថភាព និងសម្របសម្រួលដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៨.ពង្រឹងភាពជាដៃគូជាមួយអាជ្ញាធរពាក់ព័ន្ធ និងអង្គការជាដៃគូក្នុងការស្វែងរកការគាំទ្រដើម្បីបង្កើនការទទួលសេវាបង្ការ ថែទាំ និងគាំទ្រដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

- សកម្មភាពសំខាន់ៗរបស់អង្គការដៃគូ៖

១. ផ្នែកបង្ការ: មានអង្គការ AHF, KHEMARA, MHSS, MHC, SIT

- អប់រំ
- ចែកស្រោមអនាម័យ
- បញ្ជូនទៅរកសេវាពិនិត្យសុខភាព
- តេស្តឈាម
- ការគ្រប់គ្រងករណី

២. ផ្នែកព្យាបាល ថែទាំ និងគាំទ្រ: មានអង្គការ MEC, RHAC, CHOUK SOR, CPN+, AHF៖

- ការធ្វើតេស្តឈាម
- ការពិនិត្យជំងឺកាមរោគ
- ការពិនិត្យជំងឺទូទៅ
- ការផ្តល់ថ្នាំ Pre-ART and ART
- ការបញ្ជូនទៅរកសេវា

ចំនួនក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់បានទទួលការអប់រំ៖

| ល.រ | រាជធានី ខេត្ត | (MSM) | (TG) | ចំនួនសរុប | MSM&TG |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | 3411 | 769 | 4180 | MHSS, MHC, SIT and KHEMERA |
| ២ | សៀមរាប | 855 | 311 | 1166 | MHC |
| ៣ | បាត់ដំបង | 2754 | 303 | 3065 | MHSS |
| ៤ | បន្ទាយមានជ័ | 1780 | 184 | 1964 | MHSS |
| ៥ | ពោធិសាត់ | 568 | 59 | 627 | MHSS |
| ៦ | កំពង់ឆ្នាំង | 548 | 57 | 605 | MHSS |
| ៧ | កំពង់ស្ពឺ | 496 | 51 | 547 | MHSS |
| ៨ | ព្រះសីហនុ | 250 | 50 | 300 | KHEMERA |
| ៩ | កោះកុង | 300 | 33 | 333 | MHC |
| ១០ | កំពង់ចាម | 461 | 52 | 513 | MHC |
| ១១ | កណ្តាល | 897 | 278 | 1175 | MHC& SIT |
| ១២ | ព្រៃវែង | 497 | 49 | 546 | MHSS |

| | | | | | |
|---|---|---|---|---|---|
| ១៣ | កំពង់ធំ | 518 | 54 | 572 | MHSS |
| ១៤ | ប៉ៃលិន | 292 | 30 | 322 | MHSS |
| | សរុប | 13627 នាក់ | 2280នាក់ | 15907នាក់ | |




ចំនួនក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់បានធ្វើតេស្តឈាមរកមេរោគអេដស៍៖

| ល.រ | ខេត្ត | (HIV) | Confirmed | (+) | ប្រភព |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | 1414 | 12 | 12 | MHSS,MHC,KHEMERA,SIT, MEC,Rhac, AHF |
| ២ | បាត់ដំបង | 436 | 0 | 0 | MHSS |
| ៣ | បន្ទាយមានជ័យ | 596 | 2 | 2 | MHSS |
| ៤ | ប៉ៃលិន | 65 | 0 | 0 | MHSS |
| ៥ | ពោធិសាត់ | 112 | 0 | 0 | MHSS |
| ៦ | កំពង់ឆ្នាំង | 149 | 0 | 0 | MHSS |
| ៧ | កំពង់ស្ពឺ | 56 | 0 | 0 | MHSS |
| ៨ | កំពង់ធំ | 226 | 0 | 0 | MHSS |
| ៩ | ព្រៃវែង | 95 | 0 | 0 | MHSS |
| ១០ | កំពង់ចាម | 155 | 0 | 0 | MHC |
| ១១ | សៀមរាប | 114 | 0 | 0 | MHC |
| ១២ | កោះកុង | 43 | 0 | 0 | MHC |
| ១៣ | កណ្តាល | 270 | 2 | 2 | MHC |
| សរុប | | 3731 នាក់ | 16 នាក់ | 16 នាក់ | |

## ២.២ ការបង្ហាញពីបច្ចុប្បន្នភាពនៃការផ្តល់សេវាសុខភាពលើក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់៖

- ការប៉ាន់ប្រមាណចំនួនបុរសស្រឡាញ់បុរសនៅកម្ពុជាគឺ ៣០៨៩១នាក់
- ទីប្រជុំជន ១៦២៦៣ (៥២.៦%)
- ជនបទ  ១៤៦២៧ (៤៧.៤%)
- សកម្មក្នុងការរួមភេទ ៣០៨៩១ (៨៩.០%)
- មិនសកម្មក្នុងការរួមភេទ ៣៣៩៨ (១១.០%)
- អាចជួបមុខបាន ២០០៧៩ (៦៥.០%)
- លាក់មុខ ១០៨១២ (៣៥.០%)
- ឥរិយាបថប្រឈមនឹងមេរោគអេដស៍នៃក្រុមបុរសស្រឡាញ់បុរស៖
    - ៦០% មានដៃគូពីរ ឬច្រើនក្នុងមួយខែចុងក្រោយ
    - ៣០% ប្រើប្រាស់ស្រោមអនាម័យមិនជាប់លាប់ក្នុងការរួមភេទតាមរន្ធគូថក្នុងរយៈពេល៦ខែចុងក្រោយ
    - ទីកន្លែងពេញនិយមសំរាប់រកដៃគូរួមភេទ:
        - តាមផ្លូវសាធារណៈ: សួន និងមាត់ទន្លេ ៥៧%
        - ក្លឹប ឌីស្កូ ៤០%
        - ផ្ទះឯកជន ៣៩%
- ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងតេស្តកាមរោគរយៈពេល៦ខែចុងនៅទាបនៅឡើយ ៦៧% និង៤៩%។
- ចំនួនក្រុមបុរសស្រឡាញ់បុរសដែលបានមកពិនិត្យជំងឺកាមរោគ នៅគ្លីនិកកាមរោគ ៩៧៣នាក់ និងមានជំងឺកាមរោគ ២៧១នាក់។





## ២.៣ ការបង្ហាញរបាយការណស្តីពីការអង្កេតលក្ខណៈជីវសាស្ត្ររកអត្រាប្រេវ៉ាឡង់មេរោគ អេដស៍ និងការប្រព្រឹត្តផ្លូវភេទរបស់ក្រុមស្រីស្រស់នៅប្រទេសកម្ពុជា ២០១៦៖

- **គោលបំណងជារួម៖** តាមដានការផ្លាស់ប្តូរអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តផ្លូវភេទក្នុងចំណោមក្រុមស្រីស្រស់ក្នុងប្រទេសកម្ពុជា។
- **គោលបំណងជាក់លាក់៖**
  - ស្វែងរកមើលអត្រាប្រេវ៉ាឡង់លើក្រុមស្រីស្រស់
  - ពិនិត្យមើលការប្រព្រឹត្ត និងកត្តានានាដែលមានឥទ្ធិពលដល់ការប្រព្រឹត្ត
  - មើលពីសក្តានុពលតំបន់គ្របដណ្តប់កម្មវិធីបង្ការមេរោគអេដស៍ ក្នុងចំណោមក្រុមស្រីស្រស់

**អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមស្រីស្រស់តាមបណ្តាខេត្ត៖**



### អត្រាប្រេវ៉ាឡង់មេរោគអេដស៍តាមតំបន់៖




### អត្រាប្រេវ៉ាឡង់មេរោគអេដស៍តាមក្រុមអាយុ៖




- អត្រាប្រេវ៉ាឡង់មេរោគអេដស៍៖
  - អត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់៥.៩% ពិសេសនៅខេត្តបន្ទាយមានជ័យ ១១.៧% សៀមរាប ១១.៣% និងរាជធានីភ្នំពេញ ៦.៥%។
  - អត្រានេះខ្ពស់ជាងការធ្វើការសិក្សាដូចគ្នាកាលពីឆ្នាំ២០១២(៥.៩% &៤.២% សម្រាប់តួលេខរួម)ឬ(៧.១% &៤.២%បើសម្រាប់ការប្រៀបធៀតំបន់ដូចគ្នា)។
  - អត្រាប្រេវ៉ាឡង់ខ្ពស់នៅក្នុងទីក្រុងជាងនៅតំបន់ជនបទ (៦.៥% និង២.៦%)។
  - អត្រាប្រេវ៉ាឡង់ខ្ពស់ក្នុងក្រុមអាយុចន្លោះពី៣៥ ដល់៤៤(១៣.១%) អាយុច្រើនជាង ៤៥ឆ្នាំ(១១.៤%) និង២៥ ដល់៤៣ឆ្នាំ(៨.២%)។

លទ្ធផលសំខាន់ៗ - ឥរិយាបថប្រឈមនានា

- **ឥរិយាបថនៃការរួមភេទ៖**
  - ប្រើប្រាស់ស្រោមអនាម័យពេលរួមភេទតាមរន្ធគូថលើកចុងក្រោយ: ៦១.៩%។
  - ការប្រើប្រាស់ស្រោមអនាម័យជាប់លាប់ជាមួយដៃគូរួមភេទជាមួយបុរស ដោយ មិនដោះដូរជាប្រាក់៣ខែចុងក្រោយ: ៣៧.៩%។
  - ការប្រើប្រាស់ស្រោមអនាម័យជាប់លាប់ជាមួយដៃគូរួមភេទជាបុរស ដោយដោះដូរជាប្រាក់ ៣ខែចុងក្រោយ : ៦0.0%។
- **រោគសញ្ញាជំងឺកាមរោគក្នុងរយៈពេល១២ខែចុងក្រោយ៖**
  - ទទួលការថែទាំ: ៧១.៨%
  - រោគសញ្ញា: ១៤.0%
- **ធ្វើតេស្តមេរោគអេដស៍៖**
  - ធ្លាប់ធ្វើតេស្ត: ៨១.៤%
  - ៦ខែចុងក្រោយ: ៤៤.៣%

**៦-បញ្ហាប្រឈមៈ**

១.ក្រុមបុរសស្រឡាញ់បុរសមិនបានធ្វើតេស្តឈាម ដោយសារគាត់គិតថាការប្រព្រឹត្តរបស់គាត់មិនមានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ទេ។

២.ក្រុមគោលដៅមួយចំនួនមានការចល័តនៅលាក់មុខ និងមិនហ៊ានទទួលយកសេវាសុខភាពទូលំទូលាយនៅឡើយទេ។

៣.ពិបាកក្នុងប្រមូលរបាយការណ៍ និងករណីអំពើហឹង្សា ការរើសអើង និងមាក់ងាយដើម្បីចងក្រងឯកសារ ព្រោះបណ្តាញសមាគមន៍ដែលធ្វើការងារជាមួយសិទ្ធិ និងការស្វែងរកការគាំទ្រមិនបានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែ និងត្រីមាសរបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ។

៤.អង្គការអនុវត្តផ្ទាល់នៅសហគមន៍មានការខ្វះខាតសម្ភារៈសំរាប់រក្សាគុណភាពប្រតិករ។

៥.អង្គការដៃគូដែលជាសមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រឈមមុខនឹងកង្វះមូលនិធិ និងពុំមានប្រភពថវិកាច្បាស់លាស់សំរាប់អនុវត្តកម្មវិធីបន្តក្រោយពេលគម្រោងត្រូវបានបញ្ចប់នាចុងឆ្នាំ២០១៧។

៦.ការចូលរួមប្រជុំរបស់បណ្តាញចតុមុខមិនបានទៀងទាត់។

៧.ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ខ្លះពួកគាត់ជាប់រវល់ការងារកំឡុងពេលអ្នកអប់រំតាមមូលដ្ឋានចុះធ្វើការអប់រំ និងធ្វើតេស្តឈាមនៅតាមសហគមន៍។

៨.មិនបានធ្វើតេស្តឈាមដោយគាត់ខ្លាចថាគាត់បានឆ្លងមេរោគអេដស៍

៩.ខ្លាចការមាក់ងាយ និងរើសអើងពីគ្រួសារ និងសង្គម។

១០.ការស្វែងរកករណីចម្លងថ្មីនៅមានកំរិតទាប ពិសេសក្រុមលាក់មុខមិនអាចឆ្លើយតបតាមគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ២០២៥។

១១.ការអប់រំផ្សព្វផ្សាយដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ តាមបណ្តាខេត្តនានាមិនទាន់បានទូលំទូលាយ ទាំងការអប់រំវេរិយាបទសីលធម៌សង្គម សុជីវធម៌ អត្តចរិក និងសេវាសុខភាព។

១២.ខ្វះការសិក្សាពីបរិបទរបស់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

១៣.ការផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់នៅពេលស្នើសុំមានការយឺតយ៉ាវ។

១៤.ម្ចាស់សេវាមួយចំនួនតូចមិនទាន់មានកិច្ចសម្របសម្រួលបានរលូននៅឡើយទេលើការចុះពិនិត្យ និងធ្វើតេស្តឈាមនៅតាមទីតាំង។

១៥.មិនទាន់មានការគាំទ្រឬការផ្តល់នូវការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈសង្គមសម្រាប់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីលើកកម្ពស់ជីវភាពរបស់ពួកគេ។

១៦.អង្គការដៃគូមិនមានបុគ្គលិកទទួលបន្ទុកគ្រប់គ្រងករណីវិជ្ជមាននិងក្រុមគោលដៅវិជ្ជមានមួយចំនួនមានការផ្លាស់ប្តូរលំនៅ និងមិនព្រមមកទទួលសេវាទាន់ពេលវេលា។

## ៧-សំណូមពរ និងអនុសាសន៍:

១.ត្រូវជំរុញការអប់រំ និងផ្សព្វផ្សាយដល់សហគមន៍ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ ដើម្បីកាត់បន្ថយការរើសអើង និងមាក់ងាយក្នុងសង្គម។

២.ការចុះអភិបាលកិច្ច ត្រូវមានផែនការ និងកំណត់គោលដៅច្បាស់លាស់ និងមានយុទ្ធវិធីក្នុងការចុះតាមដាន និងប្រមូលមកវិញនូវចំណុចខ្វះខាតនៅសហគមន៍ និងរកដំណោះស្រាយ។

៣.ក្នុងការសម្របសម្រួលបញ្ហាផ្សេងៗដែលកើតឡើងនៅថ្នាក់មូលដ្ឋាន យើងត្រូវប្រើប្រាស់យន្តការដែលមានស្រាប់នៅថ្នាក់ក្រោមជាតិ និងបញ្ជូនព័ត៌មានមកក្រុមការងារលេខាធិការដ្ឋានរកវិធីដោះស្រាយ និងផ្សព្វផ្សាយបន្ត។

៤.ត្រូវរកយុទ្ធវិធីថ្មីៗក្នុងការជំរុញលើកទឹកចិត្តដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រើប្រាស់ឲ្យបានជាប់លាប់នៅស្រោមអនាម័យ ពិសេសអ្នកលាក់មុខ និងជំរុញលើកទឹកចិត្តឲ្យទៅទទួលសេវាសុខភាព។

៥.ត្រូវជួយបណ្តាញថ្នាក់ជាតិក្នុងការពង្រឹងស្ថាប័ន និងដើរតួនាទីជាអ្នកសម្របសម្រួលតាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ(សហគមន៍) និងជំរុញលើកទឹកចិត្តប្អូនៗ ព្រោះប្អូនៗជាជនរងគ្រោះដែលត្រូវការជួយពីបណ្តាញក្នុងការផ្តល់ប្រឹក្សាយោបល់ និងជួយជំរុញទៅរកសេវាផ្សេងៗ។

៦.សំណូមពរសមាជិកសូមបរិចាគពេលវេលាចូលរួមប្រជុំទាំងក្រុមការងារលេខាធិការដ្ឋានក៏ដូចក្រុមការងារបច្ចេកទេសឲ្យទៀងទាត់ និងគ្រប់ៗគ្នា។ យោងតាមគោលការណ៍ក្រុមការងារ អ្នកដែលអវត្តមានបីដងត្រូវដកឈ្មោះចេញពីសមាជិកក្រុមការងារលេខាធិការដ្ឋាន។

៧. សូមជួយផ្តល់របាយការណ៍ ឬទិន្នន័យលើការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលស្នើសុំពីលេខាធិការដ្ឋាន(បានការសម្របសម្រួលពី HACC)។

៨. ព្យាយាមស្វែងរកក្រុមគោលដៅថ្មី និងតាមដានគ្រប់ករណីដែលបានរកឃើញ និងផ្តល់ការប្រឹក្សាបន្ថែមអំពីបញ្ហាសុខភាព ឥរិយាបទ សុជីវធម៌ និងសីលធម៌សង្គមដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

៩. អាទិភាពកម្មវិធីផែនការសកម្មសម្រាប់ក្រុមស្រីស្រស់ ពិសេសស្រីស្រស់វ័យចំណាស់ និងនៅទីប្រជុំជនតាមរយៈការសិក្សាថ្មីៗរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ នៃក្រសួងសុខាភិបាលដែលបង្ហាញនូវអត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់ក្នុងចំណោមក្រុមស្រីស្រស់ ៥.៩%។

១០. ជំរុញការអប់រំបន្ថែមទៀតទៅលើការប្រើប្រាស់ស្រោមអនាម័យ ការធ្វើតេស្តឈាម ជំងឺកាមរោគ ការចាក់អរម៉ូនដោយខ្លួនឯង និងការចាក់គ្រឿងញៀន។

១១.ក្រុមការងារលេខាធិកាដ្ឋានរៀបចំឯកសារផ្សេងៗទាក់ទងក្រុមការងារបុរសស្រឡាញ់បុរស និងស្រីស្រស់ឆ្នាំ២០១៦ បញ្ចូនក្នុងវេបសាយរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៨-ផែនការបន្ទាប់:

១.សម្របសម្រួលរៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន និងប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរសនិងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

២.បន្តរិះរកយុទ្ធវិធីដើម្បីចូលទៅដល់ក្រុមដែលលាក់មុខ ក្រុមប្រឈមមុខខ្ពស់ ដែលមិនបាន

អប់រំ ដើម្បីឲ្យពួកគេទទួលបានព័ត៌មានអំពីសុខភាព និងតាមដានអ្នកដែលមាន ផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានសេវា PreART/ART។



៣.សម្របសម្រួលរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារថ្នាក់ក្រោមជាតិនៃបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

៤.រៀបចំកិច្ចប្រជុំ និងអញ្ជើញក្រុមការងារបណ្តាញដែលកំពុងធ្វើការលើផ្នែកស្វែងរកការគាំទ្ររួមចូលក្នុងកិច្ចប្រជុំលេខាធិការដ្ឋានប្រចាំខែ ក្នុងគោលបំណងដើម្បីពិភាក្សា និងធ្វើបច្ចុប្បន្នភាពការអនុវត្តសកម្មភាពការងារ។

៥.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ក្នុងខេត្តពោធិ៍សាត់ បាត់ដំបង និងសៀមរាប។

៦.ស្នើរសុំថវិកាពីម្ចាស់មូលនិធិ ដើម្បីទិញទូរទឹកកកក្នុងការរក្សាគុណភាពប្រតិករ។

៧.បន្តចុះអប់រំ និងជំរុញការប្រើប្រាស់ស្រោមអនាម័យ និងទឹករំអិលដល់ក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅពេលពួកគេចុះអប់រំជាក្រុម ឬអប់រំនៅតាមផ្ទះ។

៨.បន្តពង្រឹងបទអន្តរាគមន៍បង្ការ និងជំរុញក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ទៅរកសេវាពិនិត្យសុខភាព។

៩.បន្តកិច្ចសហការល្អជាមួយ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវា បុគ្គលិកអង្គការ និងអ្នកទទួលផលធ្វើអោយប្រព័ន្ធនៃការបញ្ជូនទទួលបានជោគជ័យ។

១០.ប្រមូលរបាយការណ៍ពីអង្គការដៃគូធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរសនិងស្រីស្រស់។

១១.បណ្តុះបណ្តាលដល់អ្នកអប់រំតាមសហគមន៍ឲ្យមានចំណេះដឹងក្នុងការផ្តល់ប្រឹក្សាជាកត្តាធ្វើឲ្យក្រុមគោលដៅមានទំនុកចិត្តក្នុងការទៅទទួលសេវាពិនិត្យសុខភាព។

១២.ជំរុញការធ្វើតេស្តឈាមចុងម្រាមដៃក្នុងតំបន់ hotspot ធ្វើអោយក្រុមគោលដៅមិនមានការបាត់បង់ក្នុងការទៅទទួលសេវាពិនិត្យសុខភាព។

១៣.បន្តកិច្ចសហការជាមួយអាជ្ញាធរដែនដី កងកំលាំងមានសមត្ថកិច្ច និងអង្គការសហគមន៍ និងក្រុមគោលដៅជួយការងារសង្គម ក្នុងគោលបំណងកាត់បន្ថយការមាក់ងាយ និងរើសអើងក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់។

ជាទីបញ្ចប់ ឯកឧត្តមប្រធាន បានអរគុណ និងបានកោតសរសើរចំពោះសមាជិកដែលបានចូលរួមប្រជុំនាពេលនេះ និងសូមឲ្យខិតខំបន្តសហការគ្នាល្អ និងជំរុញការងារឆ្លើយតបការទប់ស្កាត់រីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីសម្រេចបាននូវគោលការណ៍៩០ ៩០ ៩០ នាឆ្នាំ ២០២៥។

ភ្នំពេញថ្ងៃទី១៥ ខែ កញ្ញា ឆ្នាំ២០១៦

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋាន | |